# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៩០ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឱ្យអនុវត្តសូចនាករតាមដានរួមគ្នា ឆ្នាំ២០២៤-២០២៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៦៤ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៩០ សសរ ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៤ ស្តីពីសេចក្តីណែនាំស្តីពីយន្តការ និងឧបករណ៍សម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានដាក់ឱ្យអនុវត្តនូវសូចនាករតាមដានរួមគ្នា ឆ្នាំ២០២៤-២០២៨ ដូចមានចែងក្នុងតារាងភ្ជាប់នឹងសេចក្តីសម្រេចនេះ ក្នុងគោលដៅពង្រឹងភាពជាដៃគូ, បង្កើនស័ក្តិសិទ្ធិភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

និងលើកកម្ពស់គណនេយ្យភាពទ្វេទិសរវាងក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ ដើម្បីអនុវត្តគោលដៅតាមវិស័យ ដែលនឹងរួមចំណែកដល់ការអនុវត្តឱ្យបានសម្រេចនូវគោលដៅអភិវឌ្ឍន៍ជាតិ ដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។

**ប្រការ២ .-**

ប្រគល់ភារកិច្ចជូនឯកឧត្តម ឈៀង យ៉ាណារ៉ា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រធានទី២ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសម្របសម្រួលការអនុវត្តសូចនាករតាមដានរួមគ្នា ដោយសហការជាមួយបណ្ដាក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល, ក្រុមការងារបច្ចេកទេសចម្រុះ, ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ ហើយបូកសរុបលទ្ធផលនៃការអនុវត្តសូចនាករតាមដានរួមគ្នាទាំងនេះ បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំ និងពាក់កណ្ដាលអាណត្តិស្ដីពីការអនុវត្តយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ ដើម្បីគោរពជូន **សម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ពិនិត្យ និងផ្ដល់អនុសាសន៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៨ រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# សូចនាករតាមដានរួមគ្នា ឆ្នាំ២០២៤-២០២៨

ស្ថិតក្នុងបរិការណ៍នៃសុខសន្តិភាព, ស្ថិរភាពនយោបាយ និងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដោយប្រយ័ត្នប្រយែង ដើម្បីបន្តជំរុញការអភិវឌ្ឍកម្ពុជាប្រកបដោយចីរភាព និងបរិយាប័ន្ន, រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា បានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច សំដៅការពារ, ថែរក្សា និងពូនជ្រុំសមិទ្ធផលជាតិ, លើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែត, ជំរុញសម្ទុះនៃកំណើនសេដ្ឋកិច្ច, និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ។ លើមូលដ្ឋាននេះ, ជាមួយបាវចនាទាំង ៥ គឺ **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព,** រាជរដ្ឋាភិបាលបានសម្រេចកំណត់យក **គោលដៅយុទ្ធសាស្ត្រ ចំនួន ៥** និង **អាទិភាពគន្លឹះ ចំនួន ៥** សម្រាប់ **បញ្ចកោណ-ដំណាក់កាលទី ១** ។

ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១, សូចនាករតាមដានរួមគ្នាត្រូវបានប្រើប្រាស់សម្រាប់តម្រង់ទិសសកម្មភាពការងារ ដើម្បីលើកកម្ពស់លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ និងគណនេយ្យភាពទ្វេទិស ។ ទន្ទឹមនឹងនេះ ក៏ជាក្របខ័ណ្ឌសម្រាប់កំណត់គោលដៅរយៈពេលមធ្យម ស្របតាមអាទិភាពដែលមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា, កម្មវិធីកែទម្រង់, យុទ្ធសាស្ត្រតាមវិស័យ និងផែនការយុទ្ធសាស្ត្រថវិកា ។ តាមរយៈការពិភាក្សារវាងតំណាងក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធក្នុងក្រុមការងារបច្ចេកទេសចម្រុះ, សូចនាករតាមដានរួមគ្នាត្រូវបានរៀបចំ ដោយផ្អែកតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយ ឬផែនការតាមវិស័យ និងក្របខ័ណ្ឌលទ្ធផលរបស់វិស័យ ដោយផ្សារភ្ជាប់ជាមួយដំណើរការ កម្មវិធីនីយកម្ម និងថវិកានីយកម្ម ។

សូចនាករតាមដានរួមគ្នាទាំងនេះបានតម្រឹមជាមួយវិស័យអាទិភាពនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ហើយបានរំលេចនូវសកម្មភាពអាទិភាពខ្ពស់បំផុតដែលប្តេជ្ញាអនុវត្តក្នុងឆ្នាំ២០២៤-២០២៥ ហើយរាជរដ្ឋាភិបាលសូមស្វាគមន៍ចំពោះការគាំទ្ររបស់ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ ។

| **លទ្ធផលចុងក្រោយ (២០២៤-២០២៨)** | **លទ្ធផលក្នុងឆ្នាំ (២០២៤-២០២៥)** | **សូចនាករលទ្ធផលក្នុងឆ្នាំ (២០២៤-២០២៥)** |
|---|---|---|
| **ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ** : **ការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច** ផ្តោតលើការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើបប្រកបដោយសមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និងស្អាតស្អំ តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ, សេដ្ឋកិច្ច និងរដ្ឋបាល ក្នុងការដឹកនាំ, ការគ្រប់គ្រង និងការចាត់ចែងកិច្ចការប្រទេសជាតិ, ពិសេសការធានានិរន្តរភាពតួនាទី និងដំណើរការរដ្ឋបាលសាធារណៈ (ទំ. ៣៥) ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលបន្តផ្តោតលើៈ ១) ការពង្រឹង និងការកែទម្រង់ស្ថាប័ន; ២) ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ; ៣) ការលើកកម្ពស់ និងការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ; ៤) ការលើកកម្ពស់ និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌; និង ៥) ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និងធុរកិច្ច (ទំ. ៣៦) ។ | | |

| | | |
|---|---|---|
| **ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**<br><br>បូរណភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍ ទាំងក្នុងផ្នែកប្រតិបត្តិការ, និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ | ១. ភាពជឿទុកចិត្តនៃថវិកានៅរក្សាបានជាសារវន្ត | ១.១. ការកើនឡើងពិន្ទុយ៉ាងតិច ២០% សូចនាករនៃការវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA)(បន្ទាត់មូលដ្ឋាន៖ របាយការណ៍វាយតម្លៃសមិទ្ធកម្ម PEFA ឆ្នាំ២០២១ ដោយប្រើប្រាស់ក្របខ័ណ្ឌ PEFA ឆ្នាំ២០១៦)<br>១.២. អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេសក្រោម ៤០% នៃ ផ.ស.ស. (បន្ទាត់មូលដ្ឋាន៖ ពុំទាន់មាន)<br>១.៣. កំណើនចំណូលចរន្តប្រចាំឆ្នាំកើន (បន្ទាត់មូលដ្ឋាន៖ ពុំទាន់មាន) |
| | ២. ការបង្កើនប្រសិទ្ធភាព និងតម្លាភាពថវិកា | ២.១. របាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជាលើមូលដ្ឋានសាច់ប្រាក់ ត្រូវបានរៀបចំឡើង (បន្ទាត់មូលដ្ឋាន៖ សេចក្តីព្រាងរបាយការណ៍ឆ្នាំ២០២៣)<br>២.២. ស្វ័យប្រវត្តិកម្មចំណាយចរន្តតាមប្រព័ន្ធ FMIS (បន្ទាត់មូលដ្ឋាន៖ កំពុងអនុវត្តការស្វ័យប្រវត្តិកម្មថវិកាចរន្ត)<br>២.៣. ការបិទប្រតិបត្តិការថវិកាទាន់ពេលវេលានៅខែកុម្ភៈ ឆ្នាំ២០២៥ (បន្ទាត់មូលដ្ឋាន៖ ការបិទប្រតិបត្តិការថវិកាឆ្នាំ២០២៣ នៅខែមីនា ឆ្នាំ២០២៤)<br>២.៤. ឯកសារថវិកាប្រចាំឆ្នាំត្រូវបានផ្សព្វផ្សាយ និងវេទិកាសាធារណៈត្រូវបានរៀបចំ រួមមាន៖<br>ក. យ៉ាងតិចក្រសួង ស្ថាប័ន ចំនួន ៧ ផ្សព្វផ្សាយរបាយការណ៍សមិទ្ធកម្មទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ (បន្ទាត់មូលដ្ឋាន៖ ពុំទាន់មាន)<br>ខ. យ៉ាងតិចក្រសួង ស្ថាប័ន ចំនួន ៧ រៀបចំវេទិកាសាធារណៈស្តីពីថវិកាប្រចាំឆ្នាំ (បន្ទាត់មូលដ្ឋាន៖ ពុំទាន់មាន)<br>គ. យ៉ាងតិចក្រសួង ស្ថាប័ន ចំនួន ៧ រៀបចំសៀវភៅថវិកាប្រជាពលរដ្ឋ (បន្ទាត់មូលដ្ឋាន៖ ពុំទាន់មាន)<br>ឃ. សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំត្រូវបានផ្សព្វផ្សាយ បន្ទាប់ពីបញ្ជូនទៅរដ្ឋសភា (បន្ទាត់មូលដ្ឋាន៖ បានផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ២០២៤)<br>ង. ក្របខ័ណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យមត្រូវបានផ្សព្វផ្សាយ (បន្ទាត់មូលដ្ឋាន៖ បានផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ២០២៤)<br>ច. ក្របខ័ណ្ឌថវិការយៈពេលមធ្យមត្រូវបានផ្សព្វផ្សាយ(បន្ទាត់មូលដ្ឋាន៖ បានផ្សព្វផ្សាយសារាចរស្តីពីការណែនាំ រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ) |

| | | |
|---|---|---|
| | ៣. ប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ | ៣.១. ក្របខ័ណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យមត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តគណៈរដ្ឋមន្ត្រី (បន្ទាត់មូលដ្ឋាន៖ ឯកសារនេះត្រូវបានរៀបចំ ដាក់អនុវត្តដោយប្រមុខរាជរដ្ឋាភិបាល)<br>៣.២. អនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ ត្រូវបានកែសម្រួល (បន្ទាត់មូលដ្ឋាន៖ អនុក្រឹត្យលេខ ៤១ អនក្រ.បក) |
| | ៤. ក្របខ័ណ្ឌគណនេយ្យភាពសមិទ្ធកម្មត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ៤.១. កិច្ចព្រមព្រៀងថវិកាសមិទ្ធកម្មត្រូវបានដាក់ឱ្យអនុវត្តគ្រប់ក្រសួង ស្ថាប័ន (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៤៖ ក្រសួង ស្ថាប័នចំនួន ៣៨)<br>៤.២. ក្រសួង ស្ថាប័នពាក់ព័ន្ធបានរៀបចំរបាយការណ៍តាមដានកិច្ចព្រមព្រៀងសមិទ្ធកម្ម និងបញ្ជូនមក ក.ស.ហ.វ. (បន្ទាត់មូលដ្ឋាន៖ ប្រកាសស្តីពីការដាក់ឱ្យអនុវត្តយន្តការសម្រាប់ការតាមដាន វាយតម្លៃសមិទ្ធកម្ម និងលិខិតបទដ្ឋានកំណត់យន្តការតាមក្រសួង ស្ថាប័ន) |
| | ៥. ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ តាមរយៈការបង្កើនការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែង | ៥.១. ៦៥% នៃចំនួនគម្រោងលទ្ធកម្មនៃថវិកាចរន្ត ត្រូវប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែង (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៣៖ ៦០,២៩% នៃការប្រគល់កិច្ចសន្យាថវិកាចរន្តត្រូវបានប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែង)<br>៥.២. ភាពទាន់ពេលវេលាផ្សព្វផ្សាយឯកសារព័ត៌មានលទ្ធកម្មសាធារណៈ (PI-24.3 ពិន្ទុ C) (បន្ទាត់មូលដ្ឋាន៖ PI-24.3 ពិន្ទុ D) |
| **ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**<br><br>រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មានភាពធន់មាំ វៃឆ្លាត និងមានសមត្ថភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព | ១. រចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងសិទ្ធិអំណាចរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានសិក្សា រៀបចំឱ្យមានលក្ខណៈទំនើប សមស្រប តាមចរិតលក្ខណៈនៃប្រភេទរដ្ឋបាលនីមួយៗ និងមានការទទួលខុសត្រូវច្បាស់លាស់ | ១.១. ជម្រើសនានាសម្រាប់រៀបចំរដ្ឋបាលរាជធានីត្រូវបានសិក្សា<br>១.២. ជម្រើសនានាសម្រាប់ការរៀបចំរដ្ឋបាលខេត្តក្លាយជារដ្ឋបាលដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ ត្រូវបានសិក្សា និងអនុម័ត |
| | ២. ធនធានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកំណត់ទំហំសមស្រប បង្កើន និងវិភាជទៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ | ២.១. ការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលក្រុង ស្រុក ក្នុងការអនុវត្តមុខងារដែលបានផ្ទេរត្រូវបានបង្កើន<br>២.២. ក្របខ័ណ្ឌសម្រាប់បង្កើតមូលនិធិភាតរភាព ត្រូវបានសិក្សា និងរៀបចំ |

| | | |
|---|---|---|
| | ៣. ការធ្វើទំនើបកម្មការផ្ដល់សេវារដ្ឋបាលតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជូនប្រជាពលរដ្ឋ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ៣.១. ការរៀបចំ និងអនុវត្តសាកល្បងប្រព័ន្ធផ្ដល់សេវាតាមអនឡាញនៅអង្គភាពច្រកចេញ-ចូលតែមួយ ថ្នាក់រាជធានី ខេត្ត ក្នុងវិស័យមួយចំនួន |
| | ៤. ផែនការអនុវត្តការងារគណនេយ្យសង្គម ត្រូវបានសិក្សា និងបន្តពង្រីកការអនុវត្តនៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ | ៤.១. ផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលបន្ទាប់ត្រូវបានសិក្សា និងដាក់ឱ្យអនុវត្ត<br>៤.២. គោលដៅអនុវត្តការងារគណនេយ្យភាពសង្គមលើការផ្ដល់សេវារដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួន ត្រូវបានពង្រឹង និងពង្រីក |
| **ការកែទម្រង់រដ្ឋបាលសាធារណៈ**<br><br>ការលើកកម្ពស់ប្រសិទ្ធភាពការងារ និងការកែលម្អទំនើបកម្មរដ្ឋបាលសាធារណៈ ត្រូវបានរៀបចំ<br><br>ការកែលម្អការផ្ដល់សេវាសាធារណៈ ត្រូវបានរៀបចំ ពិសេសក្នុងវិស័យសំខាន់ៗ (អប់រំ និងសុខាភិបាល) | ១. កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តដោយផ្អែកលើកំណែទម្រង់ជាដំណាក់កាលៗ ដើម្បីធានាឱ្យបាននូវរដ្ឋបាលស្អាតស្អំ ឆ្លាតវៃ ខ្លាំង និងផ្ដោតលើប្រជាជនជាស្នូល | ១.១. កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈត្រូវបានអនុម័ត និងដាក់អនុវត្តដោយរាជរដ្ឋាភិបាល នៅត្រីមាសទី ៤ ឆ្នាំ២០២៤ |
| | ២. ផែនទីបង្ហាញផ្លូវសម្រាប់ការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាសម្រាប់គ្រប់គ្រងធនធានមនុស្ស (HRMIS) ត្រូវបានអនុម័ត និងអនុវត្ត (ស្របជាមួយកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ) ដោយផ្អែកលើក្របខ័ណ្ឌពេលវេលាដែលបានរៀបចំ | ២.១. ផែនទីបង្ហាញផ្លូវសម្រាប់ការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាសម្រាប់គ្រប់គ្រងធនធានមនុស្ស (HRMIS) ត្រូវបានអនុម័ត និងដាក់អនុវត្តដោយរាជរដ្ឋាភិបាល នៅត្រីមាសទី ៤ ឆ្នាំ២០២៤ |

| | | |
|---|---|---|
| | ៣. កម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពសម្រាប់មន្ត្រីរាជការស៊ីវិលស្តីពីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ ត្រូវបានរៀបចំសម្រាប់ក្រសួង ស្ថាប័ន និងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក | ៣.១. វគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ ត្រូវបានរៀបចំជាអនឡាញ និងដោយផ្ទាល់ សម្រាប់ឆ្នាំ២០២៤<br>៣.២. របាយការណ៍តាមដានវឌ្ឍនភាពការងារកែទម្រង់ប្រចាំត្រីមាសត្រូវបានរៀបចំ |
| **ការប្រយុទ្ធប្រឆាំងអំពើពុករលួយ*** <br><br>ការងារអប់រំ បង្ការ ទប់ស្កាត់ ត្រូវបានពង្រឹង និងពង្រីក | ១. ការប្រឡងចូលស្ថាប័នសាធារណៈ និងលទ្ធកម្មសាធារណៈ ត្រូវបានលើកកម្ពស់ប្រសិទ្ធភាព | ១.១. ចំនួនការងារសង្កេតការណ៍ប្រឡង<br>១.២. ចំនួនការងារសង្កេតការណ៍លទ្ធកម្មសាធារណៈ |
| | ២. ការចូលរួមរបស់វិស័យឯកជនត្រូវបានពង្រីក | ២.១. ចំនួន MOU និងចំនួនក្រុមហ៊ុនសាជីវកម្មដែលបានសហការជាមួយ អ.ប.ព. |
| **ការកែទម្រង់ប្រព័ន្ធយុត្តិធម៌**<br><br>សេវាកម្មយុត្តិធម៌ និងសិទ្ធិទទួលបានយុត្តិធម៌ដែលត្រូវបានកែលំអ | ១. ច្បាប់ និងគោលនយោបាយពាក់ព័ន្ធវិស័យយុត្តិធម៌ ត្រូវបានធ្វើទំនើបកម្ម និងដាក់ឱ្យអនុវត្ត | ១.១. ការបង្កើនចំនួនចៅក្រម និងព្រះរាជអាជ្ញា (មូលដ្ឋានគិត ឆ្នាំ២០២៣៖ ៦៥៦នាក់; គោលដៅកើនឡើង ៩% ជារៀងរាល់ឆ្នាំ)<br>១.២. ការរក្សាកញ្ចប់ថវិកាជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ (មូលដ្ឋានគិត ឆ្នាំ២០១៩៖ ២.៦០០ លានរៀល; ទិសដៅបង្កើន 0% ជារៀងរាល់ឆ្នាំ)<br>១.៣. សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា សាការី ក្រឡាបញ្ជី ត្រូវដំណើរការដោយតម្លាភាព និងមានការពិគ្រោះយោបល់ (មូលដ្ឋានគិត៖ 0; ទិសដៅ៖ ៣)<br>១.៤. ការធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី (មូលដ្ឋានគិត៖ 0; ទិសដៅ៖ ២)<br>១.៥. វិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវីត្រូវបានអនុម័ត<br>១.៦. ចំនួនអ្នកត្រូវផ្តន្ទាទោសដែលសម្រេចមិនឃុំខ្លួន(មូលដ្ឋានគិត៖ ៣%; ទិសដៅ៖ ១០%)<br>១.៧. ចំនួនមនុស្សត្រូវបានផ្តន្ទាទោសដោយមិនឃុំខ្លួន(មូលដ្ឋានគិត៖ ៩%; ទិសដៅ៖ ១៥%) |

* សូចនាករតាមដានត្រូវបានកំណត់ដោយអង្គភាពប្រឆាំងអំពើពុករលួយ សម្រាប់អនុវត្ត និងតាមដានវឌ្ឍនភាព

| | | |
|---|---|---|
| | ២. ការរៀបចំអង្គតុលាការ ត្រូវបានពង្រឹង | ២.១. ការបង្កើតតុលាការពាណិជ្ជកម្ម<br>២.២. ការកសាងសមត្ថភាពសម្រាប់ចៅក្រម, មន្ត្រីក្រសួងយុត្តិធម៌ និងមន្ត្រីនៃបណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា (មូលដ្ឋានគិត៖ 0; ទិសដៅ៖ ៥ រៀងរាល់ឆ្នាំ) |
| | ៣. ការគ្រប់គ្រងសំណុំរឿង និងព័ត៌មានត្រូវបានកែលម្អ | ៣.១. សំណុំរឿងកកស្ទះនៅតាមសាលាដំបូងត្រូវបានកាត់បន្ថយ<br>ក. សម្រាប់រឿងរដ្ឋប្បវេណី (មូលដ្ឋានគិត៖ ៣០%; ទិសដៅ៖ ៥០%)<br>ខ. សម្រាប់រឿងព្រហ្មទណ្ឌ (មូលដ្ឋានគិត៖ ៥០%; ទិសដៅ៖ ៧០%)<br>៣.២. របាយការណ៍វាយតម្លៃពីការចុះបញ្ជីការតុលាការនៅតាមសាលាដំបូង ត្រូវបានបញ្ចប់ (មូលដ្ឋានគិត៖ 0; ទិសដៅ៖ ១)<br>៣.៣. ចំនួនសាលក្រមរដ្ឋប្បវេណីសម្រាំងត្រូវបានបោះពុម្ព (មូលដ្ឋានគិត៖ ៣0; ទិសដៅ៖ ១០០)<br>៣.៤. ចំនួនសាលក្រមព្រហ្មទណ្ឌសម្រាំងត្រូវបានបោះពុម្ព (មូលដ្ឋានគិត៖ 0; ទិសដៅ៖ ៥0) |
| **ផែនការ និងការកាត់បន្ថយភាពក្រីក្រ**<br><br>គោលដៅអាទិភាពជាតិ រួមទាំង គ.អ.ច.ក. ត្រូវបានធ្វើឱ្យសម្រេចបាន តាមរយៈការអនុម័ត និងអនុវត្ត ផ.យ.អ.ជ. ហើយការអនុវត្តនេះនឹងត្រូវបានវាយតម្លៃដោយផ្អែកលើទិន្នន័យ និងស្ថិតិដែលមានគុណភាព ដែលជាផ្នែកមួយនៃប្រសិទ្ធភាពប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | ១. ផ.យ.អ.ជ. ២០២៤-២០២៨ ត្រូវបានអនុវត្តពេញលេញជាមួយគ្នានឹងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ការរៀបចំផែនការ និងយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃត្រូវបានពង្រឹង ហើយរបាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ២០២៦ នៃការអនុវត្ត ផ.យ.អ.ជ. ២០២៤-២០២៨ និងរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ២០២៥ នៃការសម្រេចបាន គ.អ.ច.ក. រៀបចំ និងអនុម័ត | ១.១. ផ.យ.អ.ជ. ២០២៤-២០២៨ ត្រូវបានរៀបចំ អនុម័ត និងផ្សព្វផ្សាយ<br>១.២. ផ.យ.អ.ជ. ២០២៤-២០២៨ ត្រូវបានអនុវត្តពេញលេញ តាមរយៈ ផ.យ.អ.វ. ផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ<br>១.៣. ក.វ.ស. ៣ឆ្នាំរំកិល ត្រូវបានរៀបចំតាមវដ្ដនៃការរៀបចំ និងត្រូវបានបញ្ជូនទៅសុំការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា ។ ក.វ.ស. ត្រូវបានប្រើប្រាស់ឯកសារយោង សម្រាប់ការរៀបចំថវិកាជាតិប្រចាំឆ្នាំ<br>១.៤. របាយការណ៍វឌ្ឍនភាព ឆ្នាំ២០២៤ នៃការអនុវត្ត ផ.យ.អ.ជ. ត្រូវបានរៀបចំបញ្ចប់ និងអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា<br>១.៥. ការពង្រឹងសុខដុមនីយកម្មរវាងផែនការថវិកា និងការសម្របសម្រួលជំនួយ (តាមរយៈការផ្សារភ្ជាប់រវាងការរៀបចំផែនការ និងការរៀបចំថវិកា)<br>១.៦. ភស្តុតាងត្រូវបានបង្កើតឡើង ដើម្បីផ្ដល់ដំណឹងពីអន្តរាគមន៍ពីការកាត់បន្ថយភាពក្រីក្រ និងរបាយការណ៍ពីការវាស់វែងភាពក្រីក្រ រួមទាំងភាពក្រីក្ររបស់កុមារ |

| | | |
|---|---|---|
| | ២. ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព ត្រូវបានអនុវត្ត តាមរយៈ ផ.យ.អ.ជ., ផ.យ.អ.វ. និងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ និងតាមដានត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាព | ២.១. របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០២៥ នៃការអនុវត្ត គ.អ.ច.ក. ត្រូវបានរៀបចំ និងបង្ហាញនៅក្នុងវេទិកាកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ<br>២.២. វឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ. និងការសម្រេចបាន គ.អ.ច.ក. នៅថ្នាក់ក្រោមជាតិ ត្រូវបានតាមដានត្រួតពិនិត្យ |
| | ៣. សកម្មភាពអាទិភាពប្រចាំឆ្នាំនៃ NSDS ២០១៩-២០២៣ ត្រូវបានអនុវត្តពេញលេញ | ៣.១. ការអនុវត្តជំរឿន អង្កេត និងការចងក្រងស្ថិតិ ដោយប្រើប្រាស់ទិន្នន័យរដ្ឋបាល<br>៣.២. ការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ និងការកសាងសមត្ថភាពត្រូវបានពង្រឹង និងអនុវត្ត<br>៣.៣. ការប្រើប្រាស់ និងការទទួលបានទិន្នន័យតាមរយៈការធ្វើទំនើបកម្ម ICT ត្រូវបានអនុវត្ត |
| **បញ្ហាកោណទី ១** : **ការអភិវឌ្ឍធនធានមនុស្ស** - ការអភិវឌ្ឍមូលធនមនុស្ស គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន សម្រាប់ជំរុញពិពិធកម្ម និងកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងភាពធន់ ។ មូលធនមនុស្សមានគុណភាពខ្ពស់ និងសុខភាពល្អ គឺជាទ្រព្យសកម្មជាតិដ៏រឹងមាំសម្រាប់បង្កើនតម្លៃសេដ្ឋកិច្ច, លើកកម្ពស់តម្លៃវប្បធម៌ និងបង្កើតគំនិតថ្មីៗ សំដៅធានាចីរភាពកំណើនរយៈពេលវែង និងជវភាពការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលផ្តោតលើអាទិភាព ៥ : ១) ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា; ២) ការបណ្តុះបណ្តាលជំនាញបច្ចេកទេស; ៣) ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន; ៤) ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង និង ៥) ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌, សមធម៌ និងបរិយាប័ន្ន (ទំ. ៥១-៥២) ។ | | |
| **ការអប់រំ**<br><br>ភាគរយនៃចំនួនសិស្សថ្នាក់ទី ១២ ដែលបានបញ្ចប់ការសិក្សា ទទួលបាននិទ្ទេស A, B, C (២០២៨ = ៣៥%) | ១. ចំនួនសាលារៀន (មត្តេយ្យសិក្សា, បឋមសិក្សា, មធ្យមសិក្សា) បានបំពេញតាមស្តង់ដាសាលារៀនគំរូ | ១.១. ចំនួនសាលារៀន (មត្តេយ្យសិក្សា, បឋមសិក្សា, មធ្យមសិក្សា) បានបំពេញតាមស្តង់ដាសាលារៀនគំរូ (ឆ្នាំគោល ២០២៣៖ ១២០; ចំណុចគោលដៅ ឆ្នាំ២០២៤៖ ២៥០) |
| | ២. ចំនួនគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាល ១២+៤ និងបរិញ្ញា+២ | ២.១. ចំនួនគ្រូបង្រៀនទទួលការបណ្តុះបណ្តាល ១២+៤ (បឋមសិក្សា និងមធ្យមសិក្សា) (ឆ្នាំគោល ២០២៣-២០២៤៖ ៥៩០ និង ៣៧៩; ចំណុចគោលដៅ ឆ្នាំ២០២៤-២០២៥៖ ១.៣៧០ និង ៧១៩)<br>២.២. ចំនួនគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាល បរិញ្ញា+២ (ឆ្នាំគោល ២០២៣-២០២៤៖ 0; ចំណុចគោលដៅ ឆ្នាំ២០២៤-២០២៥៖ ៧៤០) |
| | ៣. ចំនួនគ្រូបង្រៀនដែលទទួលបានការបណ្តុះបណ្តាលការរៀនថ្នាក់ដំបូង (ថ្នាក់ទី១-៣) | ៣.១. ចំនួនគ្រូបង្រៀនទទួលការបណ្តុះបណ្តាលអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង (ឆ្នាំគោល ២០២៣-២០២៤៖ ១៦.៣៤៣ និង ៥.១១៦; ចំណុចគោលដៅ ឆ្នាំ២០២៤-២០២៥៖ ២០.០០០ និង ៧.០០០) |

| | | |
|---|---|---|
| **ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ:**<br><br>ការបង្កើនលទ្ធភាពទទួលបានការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ.) ប្រកបដោយគុណភាព ឱ្យឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ៤.0, សេដ្ឋកិច្ច-សង្គមឌីជីថល និង សេដ្ឋកិច្ចបៃតង | ១. ការពង្រឹងគុណភាព អ.ប.វ. ដោយរួមបញ្ចូលនូវជំនាញសម្បទាការងារ (Employability Skills), ជំនាញសម្បទាបត់បែន (Adaptability Skills), ជំនាញបច្ចេកវិទ្យាឌីជីថល និងជំនាញបៃតង | ១.១. ភាគរយនៃសិក្ខាកាម សិស្ស និងនិស្សិតបានបញ្ចប់ការបណ្តុះបណ្តាលនិងមានការងារធ្វើ (ឆ្នាំ២០២៣៖ ៨០%; គោលដៅ ឆ្នាំ២០២៥៖ យ៉ាងតិច ៨០%)<br>១.២. ភាគរយនៃការពេញចិត្តរបស់និយោជក លើសិក្ខាកាម សិស្ស និស្សិត ក្នុងវិស័យ អ.ប.វ. (ឆ្នាំ២០២៣៖ ៧០% ; គោលដៅ ឆ្នាំ២០២៥៖ យ៉ាងតិច ៧៥%)<br>១.៣. ចំនួនគុណវុឌ្ឍិសម្រាប់កញ្ចប់ស្តង់ដាបណ្តុះបណ្តាល (ស្តង់ដាសមត្ថភាព, កម្មវិធីសិក្សា និងកញ្ចប់វាយតម្លៃ) ត្រូវបានអភិវឌ្ឍ ដាក់ឱ្យប្រើប្រាស់ (ឆ្នាំ២០២៣៖ ១៨៨ គុណវុឌ្ឍិ; គោលដៅ ឆ្នាំ២០២៥៖ ៣០៨ គុណវុឌ្ឍិ - តួលេខបង្គរចុងគ្រា) |
| | ២. ការពង្រីកការបណ្តុះបណ្តាលកម្លាំងពលកម្មជំនាញ ដើម្បីគាំទ្រ គោលនយោបាយអភិវឌ្ឍន៍ សេដ្ឋកិច្ច និងសង្គម | ២.១. ចំនួនសិក្ខាកាម សិស្ស និស្សិតចុះឈ្មោះចូលរៀនកម្មវិធី អ.ប.វ. (ស្រីយ៉ាងតិច ២៥%) (ឆ្នាំ២០២៣៖ ៩២.៣៦៦ នាក់; គោលដៅ ឆ្នាំ២០២៥៖ ១៩១.២៥០ នាក់)<br>២.២. ចំនួនសិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ការបណ្តុះបណ្តាលកម្មវិធី អ.ប.វ. (ស្រីយ៉ាងតិច ២៥%) (ឆ្នាំ២០២៣៖ ៨៦.២៣០ នាក់; គោលដៅ ឆ្នាំ២០២៥៖ ១៧.៨៦៥ នាក់)<br>២.៣. ចំនួនអ្នកទទួលបានការធ្វើតេស្តវាយតម្លៃទទួលស្គាល់ការសិក្សាដែលមានពីមុន និង សមត្ថភាពបច្ចុប្បន្ន(RPL/RCC) លើជំនាញអាទិភាពកើនឡើង(ស្រីយ៉ាងតិច ២៥%) (ឆ្នាំ២០២៣៖ ៥០៤ នាក់; គោលដៅ ឆ្នាំ២០២៥៖ ១០.០០០ នាក់) |
| | ៣. ការពង្រឹងភាពជាដៃគូរវាងរដ្ឋ និង ឯកជន និងដៃគូអភិវឌ្ឍ ដើម្បីធានានិរន្តរភាពនៃកម្មវិធីបណ្តុះបណ្តាល | ៣.១. ចំនួនគ្រឹះស្ថាន អ.ប.វ បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយសហគ្រាស គ្រឹះស្ថាន ដើម្បីគាំទ្រការអនុវត្តកម្មវិធី អ.ប.វ. កើនឡើង (ឆ្នាំ២០២៣៖ ៦៣ MOUs; គោលដៅ ឆ្នាំ២០២៥៖ ៣៧០ MOUs)<br>៣.២. ចំនួនសិស្ស និស្សិតដែលបានចុះធ្វើកម្មសិក្សានៅតាមសហគ្រាស កើនឡើង (ឆ្នាំ២០២៣៖ ៥.៧០៧ នាក់; គោលដៅ ឆ្នាំ២០២៥៖ ៧.៥៣០ នាក់)<br>៣.៣. អ្នកបច្ចេកទេសមកពីឧស្សាហកម្ម និងគណៈវិស្វករកម្ពុជា/ស្ថាប័នជំនាញ ចូលរួមផ្តល់ការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថាន អ.ប.វ. (ឆ្នាំ២០២៣៖ សូចនាករថ្មីពុំទាន់មានទិន្នន័យ; គោលដៅ ឆ្នាំ២០២៥៖ ២៥០ នាក់) |

| | | |
|---|---|---|
| **សុខាភិបាល**<br><br>ប្រព័ន្ធសុខាភិបាលជាតិ ដែលមានមុខងារ និងមាននិរន្តរភាពហិរញ្ញប្បទានដែលឈានទៅរកការគ្របដណ្តប់សុខភាពជាសកល និងការពង្រឹងសន្តិសុខសុខភាពដល់ប្រជាជនកម្ពុជាទូទៅទាំងអស់ ជាពិសេសប្រជាជនក្រីក្រ និងងាយរងគ្រោះ | ១. [ការគ្របដណ្តប់សុខភាពជាសកល] ការបង្កើនលទ្ធភាពទទួលបាន និងប្រើប្រាស់សេវាអាទិភាពជាមួយការការពារផ្នែកហិរញ្ញវត្ថុ | ១.១. សន្ទស្សន៍នៃការគ្របដណ្តប់សេវាកម្មនៃការគ្របដណ្តប់សុខភាពជាសកល (សូចនាករដើមគ្រា៖ ៥៨ គិតត្រឹមឆ្នាំ ២០២១ - ផែនទីបង្ហាញផ្លូវនៃការគ្របដណ្តប់សុខភាពជាសកល; គោលដៅឆ្នាំ២០២៨៖ ៦៤ - ផែនទីបង្ហាញផ្លូវនៃការគ្របដណ្តប់សុខភាពជាសកល) |
| | ២. [គុណភាពថែទាំ] ការលើកកម្ពស់គុណភាពថែទាំនៅតាមសេវាសុខភាពសាធារណៈ និងឯកជន | ២.១. ភាគរយមូលដ្ឋានសុខាភិបាលទទួលបានពិន្ទុគុណភាពយ៉ាងហោចណាស់ ៥០% (DHS)<br>• សូចនាករដើមគ្រា ឆ្នាំ២០២៣៖ ៥% (៧៥/១.៤០០)<br>➢ មន្ទីរពេទ្យ = ១៦/១១៩ = ១៣%<br>➢ HC = ២៩/១.២៨១ = ៥%<br>• គោលដៅសម្រាប់ឆ្នាំ២០២៨៖ ២៩% (៤០២/១.៤០៩)<br>➢ មន្ទីរពេទ្យ = ៥២/១២០ = ៤៣%<br>➢ HC = ៣៥០/១.២៨៩ = ២៧% |
| | ៣. [សន្តិសុខសុខភាព] ការលើកកម្ពស់សមត្ថភាពទប់ស្កាត់ ការស្រាវជ្រាវ និងឆ្លើយតបទៅនឹងការគំរាមកំហែងសុខភាពសាធារណៈ | ៣.១. ភាគរយសូចនាករ SPAR ដែលសម្រេចបានពិន្ទុ ៣ ឬខ្ពស់ជាងនេះ ស្របតាមបទប្បញ្ញត្តិសុខភាពអន្តរជាតិ (IHR, 2005) [CDC] (សូចនាករដើមគ្រា ឆ្នាំ២០២៤៖ ៨៩% - នៅឆ្នាំ២០២៣ សូចនាករ SPAR ចំនួន ៣១/៣៥ ត្រូវបានវាយតម្លៃថាមានពិន្ទុ ៣ ឬ ៤ តាមមាត្រដ្ឋានពី ១ ដល់ ៥; គោលដៅ ឆ្នាំ២០២៨៖ ៩១%) |
| **មេរោគអេដស៍ និងជំងឺអេដស៍**<br><br>បញ្ចប់មេរោគអេដស៍ ជំងឺអេដស៍ ដែលជាការគំរាមកំហែងដល់សុខភាពសាធារណៈ និងគោលដៅ៩៥-៩៥-៩៥ | ១. ការសម្រេចបានគោលដៅ ៩៥-៩៥-៩៥ | ១.១. ភាគរយនៃអ្នកផ្ទុកមេរោគអេដស៍ដឹងពីស្ថានភាពរបស់ខ្លួន (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២២៖ ៨៩%; គោលដៅ ឆ្នាំ២០២៥៖ ៩៥%)<br>១.២. ភាគរយនៃអ្នកផ្ទុកមេរោគអេដស៍ដែលដឹងពីស្ថានភាពរបស់ខ្លួន ទទួលបានសេវាព្យាបាល និងថែទាំមេរោគអេដស៍ (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២២៖ ៩៩%; គោលដៅ ឆ្នាំ២០២៥៖ ៩៩%)<br>១.៣. ភាគរយនៃអ្នកដែលទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ មានបន្ទុកមេរោគអេដស៍ដែលត្រូវបានបង្ក្រាបក្នុងកម្រិតទាបបំផុត (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២២៖ ៩៨%; គោលដៅ ឆ្នាំ២០២៥៖ ៩៩%) |

| | | |
|---|---|---|
| | ២. ក្រុមអ្នកផ្ទុកមេរោគអេដស៍(PLHIV), ក្រុមប្រជាជនគន្លឹះ(KPs), ស្ត្រីបម្រើសេវាកម្សាន្ត(EW), បុរសរួមភេទជាមួយបុរស(MSM), ក្រុមបំប្លែងភេទ, ក្រុមប្រើគ្រឿងញៀនដោយចាក់(PWID) និងក្រុមប្រើគ្រឿងញៀន (PWUD) ត្រូវបានគ្របដណ្តប់ដោយសេវាគាំពារសង្គម | ២.១. ភាគរយនៃអ្នកផ្ទុកមេរោគអេដស៍ (PLHIV) ត្រូវបានគ្របដណ្តប់ដោយសេវាគាំពារសង្គម (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៣៖ ៥២%; គោលដៅ ឆ្នាំ២០២៥៖ ៩៥%)<br>២.២. ភាគរយនៃក្រុមប្រជាជនគន្លឹះ (KPs) ត្រូវបានគ្របដណ្តប់ដោយសេវាគាំពារសង្គម (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៥៖ គ្មាន; គោលដៅ ឆ្នាំ២០២៥៖ ២៥%) |
| | ៣. ការបង្កើនការវិនិយោគក្នុងស្រុកសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ | ៣.១. ភាគរយនៃការផ្តល់ហិរញ្ញវត្ថុសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ ជាធនធានក្នុងស្រុក (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២២៖ ៣១% - NASA VII; គោលដៅ ឆ្នាំ២០២៥៖ ៣៩%) |
| **ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**<br><br>ការអភិវឌ្ឍរបបសន្តិសុខសង្គមតាមការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច តាមរយៈការធានាការពារសន្តិសុខ និងស្ថិរភាពប្រាក់ចំណូលរបស់កម្មករនិយោជិតទាំងក្នុងវិស័យឯកជន និងវិស័យសាធារណៈ និងនិវត្តជន | ១. ការពង្រឹង និងពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គមស្របតាមការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច | ១.១. ចំនួនសមាជិក ប.ស.ស. មានការកើនឡើង (ឆ្នាំ២០២៣៖ ៣០៣.៨៧៤ នាក់; គោលដៅ ឆ្នាំ២០២៥៖ ចំនួនកើនឡើងជារៀងរាល់ឆ្នាំ)<br>១.២. ចំនួនសហគ្រាសមានការកើនឡើងយ៉ាងតិច ៥.០០០ សហគ្រាស/ឆ្នាំ (ឆ្នាំ២០២៣៖ ៤.៩៥៧ សហគ្រាស; គោលដៅ ឆ្នាំ២០២៥៖ ៥.០០០ សហគ្រាស)<br>១.៣. រាល់បណ្ណាមូលនិធិសុខាភិបាលដែលស្នើសុំ និងគ្រប់លក្ខខណ្ឌ ត្រូវបានផ្តល់ជូនទាន់ពេលវេលា (ឆ្នាំ២០២៣៖ ១០០%; គោលដៅ ឆ្នាំ២០២៥៖ ១០០%) |
| | ២. ការពង្រឹង និងបង្កើនគុណភាពនិងសមត្ថភាពផ្តល់សេវាសន្តិសុខសង្គម | ២.១. ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ ឆ្នាំ ត្រូវបានបើកផ្តល់ស្របតាមគោលការណ៍និងទាន់ពេលវេលា(ឆ្នាំ២០២៣៖ ១០០%; គោលដៅឆ្នាំ២០២៥៖ ១០០%)<br>២.២. ការទាមទារតាវកាលិក (រួមទាំងការបើកផ្តល់ប្រាក់ឧបត្ថម្ភនានា) ត្រូវបានទូទាត់ត្រឹមត្រូវ និងទាន់ពេលវេលា(ឆ្នាំ២០២៣៖ ១០០%; គោលដៅ ឆ្នាំ២០២៥៖ ១០០%) |
| | ៣. ការលើកកម្ពស់ការយល់ដឹង និងពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម | ៣.១. សមាជិក ប.ស.ស. មានទំនុកចិត្តខ្ពស់លើការអនុវត្តរបបសន្តិសុខសង្គមយ៉ាងតិច ៩០% (ឆ្នាំ២០២៣៖ សូចនាករថ្មីពុំទាន់មានទិន្នន័យ; គោលដៅ ឆ្នាំ២០២៥៖ ៩០%)<br>៣.២. សមាជិក ប.ស.ស. មានការយល់ដឹងពីតាវកាលិកនៃរបបសន្តិសុខសង្គមយ៉ាងតិច៩០% (ឆ្នាំ២០២៣៖ សូចនាករថ្មីពុំទាន់មានទិន្នន័យ; គោលដៅ ឆ្នាំ២០២៥៖ ៩០%) |

| | | |
|---|---|---|
| **សន្តិសុខស្បៀង និងអាហារូបត្ថម្ភ**<br><br>ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជាគ្រប់រូប ជាពិសេសជនក្រីក្រ អសន្តិសុខស្បៀង និងជនងាយរងគ្រោះ ត្រូវបានលើកកម្ពស់តាមរយៈប្រសិទ្ធភាពនៃការសម្របសម្រួល និងប្រព័ន្ធនៃការផ្តល់សេវា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ១. យុទ្ធសាស្ត្រ និងក្របខ័ណ្ឌប្រកបដោយប្រសិទ្ធភាព និងសកម្មភាពពហុវិស័យឆ្ពោះទៅការបញ្ចប់ភាពអត់ឃ្លាន និងបញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់ត្រឹមឆ្នាំ២០៣០ ត្រូវបានធ្វើសុខដុមនីយកម្ម និងសម្របសម្រួលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រោមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ និងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ លើកទី ៣ ឆ្នាំ២០២៤-២០២៨ ដោយផ្តោតលើក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០៣០, ចលនាបង្កើនអាហារូបត្ថម្ភ, សម្ព័ន្ធដើងឯកសម្រាប់បរិវត្តកម្មប្រព័ន្ធស្បៀង, ផែនការសកម្មភាពសកល ដើម្បីឆ្លើយតបចំពោះបញ្ហាស្គមស្គាំងរបស់កុមារ និងការប្តេជ្ញាចិត្តស្តីពីអាហារូបត្ថម្ភដើម្បីការលូតលាស់ និងកំណើនរបស់កម្ពុជា | ១.១. ត្រឹមចុងឆ្នាំ២០២៦ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ លើកទី៣ ឆ្នាំ២០២៤-២០២៨ នឹងត្រូវបានបញ្ចប់; ការគណនាការចំណាយ, ការផ្សព្វផ្សាយ, និងដាក់អនុវត្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានទទួលការគាំទ្រដោយវិធានការ និងបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធនានា (ឧទា. ការប្រើប្រាស់ម្សៅទឹកដោះគោជំនួសទឹកដោះម្តាយ, ការផ្តល់អាហារបន្ថែម, ការបញ្ចូលមីក្រូសារជាតុទៅក្នុងចំណីអាហារ និងសុវត្ថិភាពម្ហូបអាហារ និងផ្សេងៗទៀត)<br>១.២. បង្កើតយន្តការវាយតម្លៃប្រចាំឆ្នាំរួម ដោយមានការចូលរួមយ៉ាងសកម្មពីបណ្តាញចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា និងដាក់ជូនលេខាធិការដ្ឋានចលនាបង្កើនអាហារូបត្ថម្ភសកល (មានរបាយការណ៍ចំនួនបីដែលនឹងត្រូវបានដាក់ជូនក្នុងអំឡុងពេលនេះ)<br>១.៣. ការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះផែនការការងារប្រចាំឆ្នាំសម្រាប់សម្ព័ន្ធដើងឯកបរិវត្តកម្មប្រព័ន្ធស្បៀង<br>១.៤. បានពិនិត្យ និងធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវស្តីពីផែនការសកម្មភាពសកល ដើម្បីឆ្លើយតបចំពោះបញ្ហាស្គមស្គាំងរបស់កុមារ<br>១.៥. បានពិនិត្យ និងធ្វើបច្ចុប្បន្នភាពការប្តេជ្ញាចិត្តស្តីពីអាហារូបត្ថម្ភដើម្បីការលូតលាស់និងកំណើន<br>១.៦. គោលការណ៍ណែនាំ និងវេទិកាពហុវិស័យ និងពហុភាគីនានា ត្រូវបានបង្កើតឡើងដើម្បីស្វែងរកការគាំទ្រ និងលើកកម្ពស់អាទិភាពដែលដឹកនាំតាមវិស័យ និងអាទិភាពរួមសម្រាប់ការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងប្រធានបទពាក់ព័ន្ធនានា រួមមានៈ របបអាហារសុខភាព, ប្រព័ន្ធស្បៀងប្រកបដោយនិរន្តរភាព, ឥរិយាបថថៃទាំប្រសើរឡើង, ទឹកស្អាតនិងអនាម័យដែលគិតគូរដល់អាហារូបត្ថម្ភ, និងទំនាក់ទំនងជំនួយសង្គម និងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងបញ្ហាអន្តរវិស័យយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ លើកទី៣ ឆ្នាំ២០២៤-២០២៨<br>១.៧. គ្រោងរចនាសម្ព័ន្ធស្ថាប័នអភិបាលកិច្ចប្រព័ន្ធស្បៀងត្រូវបានកំណត់<br>១.៨. ការវាយតម្លៃសមត្ថភាពតម្រូវការរបស់ ក.ក.ជ ត្រូវបានរៀបចំឡើង |

| | | |
|---|---|---|
| | ២. ការពង្រឹងការសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ស្ថិតក្រោមយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ លើកទី៣ ឆ្នាំ២០២៤-២០២៨, តម្រឹមសកម្មភាពដែលដឹកនាំតាមវិស័យ និងសកម្មភាពអាទិភាពរួម, បញ្ជ្រាបបញ្ហាអន្តរវិស័យ និងលើកកម្ពស់អភិបាលកិច្ច និងអាហារូបត្ថម្ភ ដែលដឹកនាំដោយសហគមន៍ឱ្យកាន់តែប្រសើរឡើង | ២.១. ការពង្រឹងយន្តការសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបន្សីការងារទឹកស្អាតនិងអនាម័យ ដែលគិតគូរដល់អាហារូបត្ថម្ភ<br>២.២. ការបង្កើតឱ្យមានអនុក្រុមការងារថ្មីៗនៅថ្នាក់ជាតិ ដើម្បីគាំទ្រសកម្មភាពអាទិភាពរួមក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ លើកទី៣ ឆ្នាំ២០២៤-២០២៨<br>២.៣. ការបង្កើតយុទ្ធសាស្ត្រដើម្បីពង្រឹងក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ រាជធានី ខេត្ត ដោយផ្អែកលើស្តង់ដាប្រតិបត្តិ នៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ លើកទី៣ ឆ្នាំ២០២៤-២០២៨ |
| | ៣. ការប្រើប្រាស់យន្តការគ្រប់គ្រងព័ត៌មាន និងចំណេះដឹង ដើម្បីប្រមូលភស្តុតាង ផ្សព្វផ្សាយ និងពិនិត្យតាមដានការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ | ៣.១. ភស្តុតាងនៃការប្រើប្រាស់ឯកសារស្រាវជ្រាវដែលមានស្រាប់បានបោះពុម្ពផ្សាយ ដើម្បីគាំទ្រគោលនយោបាយ និងការសម្រេចចិត្តសម្រាប់ការកែលម្អការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (ឧទា. ស្តីពីការវិភាគពីការបំពេញកង្វះមីក្រូសាជាតុ, ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា និងការវិភាគបន្ទាប់បន្សំនៃការអង្កេតប្រជាសាស្ត្រ និងសុខភាព, សន្ទស្សន៍ហានិភ័យអាកាសធាតុកុមារ, ការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា, ការអង្កេតស្តីពីកសិកម្មនៅកម្ពុជា ។ល។)<br>៣.២. ឱកាសជួបជាប្រចាំ ដោយផ្ទាល់ និងតាមអនឡាញ ដើម្បីផ្លាស់ប្តូរព័ត៌មាន, ជានាការចាប់យកចំណេះដឹង និងការទទួលបានធនធានចំណេះដឹងសម្រាប់អ្នកពាក់ព័ន្ធទាំងអស់<br>៣.៣. ពង្រឹងយន្តការតាមដាន និងរាយការណ៍អំពីការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ |

| | | |
|---|---|---|
| **<u>បញ្ញកោណទី ២</u>** : **<u>ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង</u>** - ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង គឺជាមូលដ្ឋាននៃការគាំទ្រកំណើន ប្រកបដោយចីរភាព និងភាពធន់ ក្នុងរយៈពេលមធ្យម និងវែង តាមរយៈការពង្រីកមូលដ្ឋានផលិតកម្ម, ការបង្កើនតម្លៃបន្ថែម, ការតភ្ជាប់ខ្សែច្រវាក់តម្លៃ និងផ្គត់ផ្គង់សកល, ព្រមទាំងការទាក់ទាញ និងការជំរុញវិនិយោគក្នុងឧស្សាហកម្មថ្មីៗដែលកំពុងលេចឡើង ។ ឈរលើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលផ្តោតលើអាទិភាពចំនួន ៥ : ១) ការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច; ២) ការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡជីស្ទីក, វិស័យថាមពល, វិស័យទឹកស្អាត និងវិស័យឌីជីថល; ៣) ការកែលម្អបរិយាកាសធុរកិច្ច និងការវិនិយោគ; ៤) ការពង្រឹងប្រសិទ្ធភាព និងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក និង ៥) ការធ្វើនវានុវត្តន៍យន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ (ទំ. ៦០) ។ | | |
| **ហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មតំបន់**<br><br>១. ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើនភាពប្រកួតប្រជែង | ១. ការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡជីស្ទិក | ១.១. ចំនួនគម្រោងដែលត្រូវអនុវត្តក្នុងផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ និងភស្តុភារកម្ម ឆ្នាំ២០២៣-២០៣៣ និងគម្រោងអភិវឌ្ឍន៍ថ្មី<br>• បន្ទាត់មូលដ្ឋាន៖ គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់-ស្ពាន, ផ្លូវដែក, ផ្លូវទន្លេ, ផ្លូវសមុទ្រ និងភស្តុភារកម្ម ចំនួន ៤៥ គម្រោង ដែលមានលទ្ធភាពក្នុងការអនុវត្ត<br>• ចំណុចដៅ ឆ្នាំ២០២៤៖ គម្រោងហេដ្ឋារចនាសម្ព័ន្ធ ចំនួន ៣០ គម្រោង ដែលមានលទ្ធភាពក្នុងការអនុវត្ត<br>• ចំណុចដៅ ឆ្នាំ២០២៥៖ គម្រោងហេដ្ឋារចនាសម្ព័ន្ធ ចំនួន ១៥ គម្រោង ដែលមានលទ្ធភាពក្នុងការអនុវត្ត |
| ២. ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាប័ន្ន | ១. ការពង្រឹងការគ្រប់គ្រង និងការធ្វើទំនើបកម្មនគរូបនីយកម្ម | ១.១. ចំនួនគម្រោងប្រព័ន្ធទឹកកខ្វក់/ទីលានកប់សំរាមដែលត្រូវអនុវត្ត<br>• បន្ទាត់មូលដ្ឋាន៖ គម្រោងប្រព័ន្ធទឹកកខ្វក់/ទីលានកប់សំរាម ចំនួន ៧ គម្រោង ដែលមានលទ្ធភាពក្នុងការអនុវត្ត<br>• ចំណុចដៅ ឆ្នាំ២០២៤៖ គម្រោងប្រព័ន្ធទឹកកខ្វក់/ទីលានកប់សំរាម ចំនួន ១ គម្រោង ដែលមានលទ្ធភាពក្នុងការអនុវត្ត<br>• ចំណុចដៅ ឆ្នាំ២០២៥៖ គម្រោងប្រព័ន្ធទឹកកខ្វក់/ទីលានកប់សំរាម ចំនួន ៦ គម្រោង ដែលមានលទ្ធភាពក្នុងការអនុវត្ត |
| **ការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ** | ១. ចំនួនអណ្តូងស្នប់ទទួលបានការសាងសង់ថ្មី សម្រាប់ប្រើប្រាស់ផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋនៅតំបន់ជនបទ | ១.១. អណ្តូងស្នប់សម្រាប់ប្រើប្រាស់ផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋនៅតំបន់ជនបទ ទទួលបានការសាងសង់ថ្មី ចំនួន ៣៧៥ អណ្តូង |

| | | |
|---|---|---|
| ១. គ្រួសារនៅតំបន់ជនបទ ៩៧% ដែលទទួលបានសេវាទឹកស្អាតជាមូលដ្ឋាននៅឆ្នាំ២០២៨<br><br>គ្រួសារនៅតំបន់ជនបទ ៣៥% ដែលទទួលបានសេវាទឹកស្អាតគ្រប់គ្រងដោយសុវត្ថិភាព នៅឆ្នាំ២០២៨ | ២. ចំនួនប្រព័ន្ធចែកចាយទឹកតាមបណ្ដាញបំពង់ខ្នាតតូចសហគមន៍ | ២.១. ប្រព័ន្ធចែកចាយទឹកតាមបណ្ដាញបំពង់ខ្នាតតូចសហគមន៍មានចំនួន ៦ ប្រព័ន្ធ |
| | ៣. ចំនួនស្ថានីយផលិតទឹកផឹកសហគមន៍ | ៣.១. ស្ថានីយផលិតទឹកផឹកសហគមន៍មានចំនួន ៣ ស្ថានីយ |
| | ៤. ចំនួនសាងសង់ស្រះសហគមន៍ត្រូវបានសាងសង់ | ៤.១. ស្រះសហគមន៍ត្រូវបានសាងសង់ ចំនួន ១០ ស្រះ |
| | ៥. ចំនួនអាងត្រងទឹកភ្លៀងចំណុះ ៤ ម ត្រូវបានសាងសង់ | ៥.១. អាងត្រងទឹកភ្លៀងចំណុះ ៤ ម ត្រូវបានសាងសង់ ចំនួន ១០០ អាង |
| | ៦. ចំនួនខ្សែនៃប្រព័ន្ធស្រោចស្រពខ្នាតតូចសាងសង់តាមខេត្តគោលដៅ | ៦.១. ខ្សែនៃប្រព័ន្ធស្រោចស្រពខ្នាតតូចសាងសង់តាមខេត្តគោលដៅមានចំនួន ២ ខ្សែ |
| ២. គ្រួសារនៅតំបន់ជនបទ ៨៨,៦% ដែលទទួលបានសេវាអនាម័យជាមូលដ្ឋាននៅឆ្នាំ២០២៨<br><br>គ្រួសារនៅតំបន់ជនបទ ៣៦% ដែលទទួលបានសេវា អនាម័យគ្រប់គ្រងដោយសុវត្ថិភាព នៅឆ្នាំ២០២៨ | ១. ចំនួនបង្គន់/គ្រួសារក្រីក្រដែលត្រូវផ្គត់ផ្គង់សម្ភារ និងសង់នៅតាមខ្នងផ្ទះគ្រួសារក្រីក្រ | ១.១. បង្គន់/គ្រួសារក្រីក្រ ដែលត្រូវផ្គត់ផ្គង់សម្ភារ និងសង់នៅតាមខ្នងផ្ទះគ្រួសារក្រីក្រ មានចំនួន ៥.០០០ បង្គន់ |
| | ២. ចំនួនបង្គន់សហគមន៍ផ្គត់ផ្គង់សម្ភារ និងសង់នៅតាមខ្នងផ្ទះគ្រួសារក្រីក្រ | ២.១. បង្គន់សហគមន៍ផ្គត់ផ្គង់សម្ភារ និងសង់នៅតាមខ្នងផ្ទះគ្រួសារក្រីក្រ មានចំនួន ២០០ បង្គន់ |
| | ៣. ចំនួនភូមិដែលត្រូវបានស្រង់ទិន្នន័យបញ្ជីសារពើភ័ណ្ឌបង្គន់អនាម័យ | ៣.១. ភូមិ ដែលត្រូវបានស្រង់ទិន្នន័យបញ្ជីសារពើភ័ណ្ឌបង្គន់អនាម័យ មានចំនួន ១៥០ ភូមិ |
| | ៤. ចំនួនភូមិដែលត្រូវបានរៀបចំផែនទីបង្គន់អនាម័យ | ៤.១. ភូមិ ដែលត្រូវបានរៀបចំផែនទីបង្គន់អនាម័យ មានចំនួន ២០ ឃុំ |
| | ៥. ចំនួនខេត្តក្នុងការរៀបចំពិធីអបអរសាទរទទួលបាន ODF | ៥.១. ខេត្តក្នុងការរៀបចំពិធីអបអរសាទរទទួលបាន ODF មានចំនួន ៣ ខេត្ត |

<table>
<tr><td rowspan="2">ការអភិវឌ្ឍវិស័យឯកជន*<br><br>បរិយាកាសអំណោយផលដល់ការធ្វើធុរកិច្ច, ការធ្វើពាណិជ្ជកម្ម និងការវិនិយោគ តាមរយៈការសម្រួល ធ្វើសាមញ្ញកម្មនីតិវិធី ពាក់ព័ន្ធ និងការធ្វើឌីជីថលភាវូបនីយកម្ម</td><td>១. ចំនួនគម្រោងវិនិយោគ និងទំហំទុនវិនិយោគ កើនឡើង</td><td>១.១. ចំនួនគម្រោងវិនិយោគ ដែលអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង ៥%<br>១.២. ទំហំទុនវិនិយោគ ដែលអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើនឡើង ៤%</td></tr>
<tr><td>២. ចំនួនគម្រោងវិនិយោគ និងទំហំទុនវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស កើនឡើង</td><td>២.១. ចំនួនគម្រោងវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស កើនឡើង ៩%<br>២.២. ទំហំទុនវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស កើនឡើង ១៨%</td></tr>
<tr><td colspan="3"><u>បញ្ហកោណទី ៣</u> : <u>ការអភិវឌ្ឍវិស័យឯកជន និងការងារ</u> - វិស័យឯកជនត្រូវបានចាត់ទុកជាក្បាលម៉ាស៊ីននៃកំណើន និងជាដៃគូសំខាន់បំផុតក្នុងការបង្កើតការងារ, ការបង្កើតគំនិតច្នៃប្រឌិត និងនវានុវត្តន៍, ការលើកកម្ពស់ផលិតភាព និងការពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងទីផ្សារតំបន់ និងសកល ។ ឈរលើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលផ្តោតលើអាទិភាពចំនួន ៥ : ១) ការអភិវឌ្ឍទីផ្សារការងារ; ២) ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម, ធុរកិច្ចថ្មី, សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ; ៣) ការពង្រឹងភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន; ៤) ការពង្រឹងការប្រកួតប្រជែង និង ៥) ការពង្រឹងប្រព័ន្ធធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ (ទំ. ៧០) ។</td></tr>
<tr><td rowspan="2">ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ<br><br>ការបង្កើត ការរក្សា និងការបង្កើនការងារជូនកម្មករនិយោជិត ទាំងក្នុង និងក្រៅប្រព័ន្ធ ដើម្បីលើកកម្ពស់ការអភិវឌ្ឍទីផ្សារការងារនៅកម្ពុជា</td><td>១. ការពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាស្វែងរកការងារ និងវេទិកាការងារ</td><td>១.១. ចំនួនព័ត៌មានឱកាសការងារត្រូវបានប្រមូលកាន់តែគ្រប់ជ្រុងជ្រោយ និងផ្សព្វផ្សាយកាន់តែទូលំទូលាយ(ឆ្នាំ២០២៣៖ ១៦៤.៧០២ កន្លែង; គោលដៅ ឆ្នាំ២០២៥៖ ១៨០.០០០ កន្លែង)<br>១.២. ចំនួនអ្នកចុះឈ្មោះស្វែងរកការងារធ្វើ រួមទាំងសិស្ស និស្សិត និងអ្នកមានជំនាញខ្ពស់ កើនឡើង (ឆ្នាំ២០២៣៖ ១៦.៥០៨ នាក់; គោលដៅ ឆ្នាំ២០២៥៖ ៧២.៥០០ នាក់)<br>១.៣. អត្រាអ្នកទទួលបានការងារធ្វើ តាមរយៈសេវាការងារសាធារណៈ កើនឡើង (ឆ្នាំ២០២៣៖ ២១%; គោលដៅ ឆ្នាំ២០២៥៖ ២៣%)</td></tr>
<tr><td>២. ការពង្រឹង និងពង្រីកសេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ</td><td>២.១. ចំនួនអ្នកប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ កើនឡើង (ឆ្នាំ២០២៣៖ ១៤ នាក់; គោលដៅ ឆ្នាំ២០២៥៖ ២៥ នាក់ - តួលេខបង្គរចុងគ្រា)<br>២.២. ចំនួនជនបង្គោលផ្នែកអាជីពនៅតាមគ្រឹះស្ថានសិក្សាកើនឡើង (ឆ្នាំ២០២៣៖ សូចនាករថ្មី ពុំទាន់មានទិន្នន័យ; គោលដៅ ឆ្នាំ២០២៥៖ ១៣៧ នាក់ - តួលេខបង្គរចុងគ្រា)<br>២.៣. ចំនួនអ្នកទទួលបានសេវាប្រឹក្សាយោបល់អាជីព ការងារ និងវិជ្ជាជីវៈ កើនឡើង (ឆ្នាំ២០២៣៖ ៣០.៧២៤ នាក់; គោលដៅ ឆ្នាំ២០២៥៖ ៣៥.០០០ នាក់)</td></tr>
</table>

* សូចនាករតាមដានត្រូវបានកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់អនុវត្ត និងតាមដានវឌ្ឍនភាព

| **បញ្ចកោណទី ៤ : ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាប័ន្ន** - ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាប័ន្ន គឺជាអភិក្រមរួម និងជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មសង្គម-សេដ្ឋកិច្ច ដើម្បីធានាឱ្យសង្គមទាំងមូលអាចត្រៀមខ្លួនបានល្អ ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមចម្រុះ និងភាពមិនប្រាកដប្រជានៃសកលភាវូបនីយកម្ម ចីរភាពបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលផ្តោតលើអាទិភាពចំនួន ៥ : ១) ការធ្វើបរមភាវូបនីយកម្មផលលាភប្រជាសាស្ត្រ, ការពង្រឹងភាពធន់ប្រជាសាស្ត្រ និងការលើកកម្ពស់សមភាពយេនឌ័រ; ២) ការគ្រប់គ្រងធនធានធម្មជាតិ, បេតិកភណ្ឌ វប្បធម៌ និង ទេសចរណ៍ ប្រកបដោយចីរភាព; ៣) ការលើកស្ទួយកសិកម្ម និង ការអភិវឌ្ឍជនបទ; ៤) ការពង្រឹងការគ្រប់គ្រង និងការធ្វើទំនើបកម្មនគរូបនីយកម្ម; និង ៥) ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង (ទំ. ៧៨-៧៩) ។ | | |
|---|---|---|
| **យេនឌ័រ**<br><br>យន្តការស្ថាប័ន និងដៃគូពាក់ព័ន្ធ បានពង្រឹង និងសម្របសម្រួល ដើម្បីបង្កើនការវិនិយោគលើសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី តាមរយៈការធ្វើបរិវត្តកម្មយេនឌ័រក្នុងក្របខ័ណ្ឌគោលនយោបាយ និងកម្មវិធីជាតិ, ការបង្ការនិងឆ្លើយតបនឹងអំពើហិង្សាលើស្ត្រីនិងក្មេងស្រី, ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច, និងលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងអភិបាលកិច្ច | ១. គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ បានអនុម័តដោយរាជរដ្ឋាភិបាល និងមានប្រតិបត្តិការដែល មានសង្គតិភាពជាមួយនឹងការប្តេជ្ញាចិត្តជាតិ និងអន្តរជាតិ ដើម្បីបង្កើនការវិនិយោគលើសមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រី | ១.១. គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ទទួលបានការអនុម័តដោយរាជរដ្ឋាភិបាល (បន្ទាត់មូលដ្ឋាន៖ មិនទាន់មាន; ចំណុចដៅ ឆ្នាំ២០២៤៖ ចំនួន ១)<br>១.២. ប្រព័ន្ធតាមដាននិងវាយតម្លៃ ក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ នៅតាមក្រសួង ស្ថាប័ន និងតាមវិស័យ បានរៀបចំតាមរយៈយន្តការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងមានការចូលរួមអនុវត្តដោយក្រសួង ស្ថាប័ន (បន្ទាត់មូលដ្ឋាន៖ មិនទាន់មាន; ចំណុចដៅ ឆ្នាំ២០២៥៖ ចំនួន ១)<br>១.៣. ផែនការយុទ្ធសាស្ត្រនារីរតនៈទី ៦ ឆ្នាំ២០២៤-២០២៨ បានផ្សព្វផ្សាយជាផ្លូវការ និងអនុវត្ត ដើម្បីពង្រឹងប្រសិទ្ធភាពមុខងាររបស់ក្រសួងកិច្ចការនារី និងក្នុងការដឹកនាំការសម្របសម្រួលអនុវត្តអភិក្រមបរិវត្តកម្មយេនឌ័រ (បន្ទាត់មូលដ្ឋាន៖ ៥; ចំណុចដៅ ឆ្នាំ២០២៤៖ ១)<br>១.៤. ចំនួនកម្មវិធីសិក្សាស្រាវជ្រាវអំពីស្ថានភាពយេនឌ័រតាមវិស័យ និងឆ្លើយតបតាមការវិវត្តថ្មីៗរបស់សង្គម (បន្ទាត់មូលដ្ឋាន៖ ឆ្នាំ២០២៣; ចំណុចដៅ ឆ្នាំ២០២៥៖ ៥)<br>១.៥. កម្មវិធីស្ថាប័នូបនីយកម្មយេនឌ័រតាមវិស័យ រួមទាំងកម្មវិធីថវិកាឆ្លើយតបយេនឌ័រ បានអនុវត្តនៅតាមក្រសួង ស្ថាប័ន (បន្ទាត់មូលដ្ឋាន៖ មិនទាន់មាន; ចំណុចដៅ ឆ្នាំ២០២៥៖ ក្រសួង ស្ថាប័ន ចំនួន ៤) |
| | ២. ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី ៤ ឆ្នាំ២០២៤-២០៣០, ផែនការសកម្មភាពជាតិស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍ | ២.១. ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី ៤ បានរៀបចំ និងដាក់ឱ្យដំណើរការ (បន្ទាត់មូលដ្ឋាន៖ ៣; ចំណុចដៅ ឆ្នាំ២០២៤៖ ៤)<br>២.២. សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បានបញ្ចប់ និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ (បន្ទាត់មូលដ្ឋាន៖ 0; ចំណុចដៅ ឆ្នាំ២០២៥៖ ១) |

| | | |
|---|---|---|
| | នៅវ័យក្មេង និងការមានផ្ទៃពោះវ័យជំទង់ បានរៀបចំ និងដាក់ឱ្យដំណើរការអនុវត្ត និងផែនទីតម្រង់ទិសឆ្ពោះទៅធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ត្រូវបានបញ្ចប់ និងដំណើរការធ្វើវិសោធនកម្មច្បាប់នេះ | ២.៣. ផែនការសកម្មភាពជាតិស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍នៅវ័យក្មេង និងការមានផ្ទៃពោះវ័យជំទង់ បានរៀបចំ និងដាក់ឱ្យអនុវត្តជាផ្លូវការ (បន្ទាត់មូលដ្ឋាន៖ ០; ចំណុចដៅ ឆ្នាំ២០២៥៖ ១) |
| | ៣. ក្របខ័ណ្ឌជាតិ ផែនការសកម្មភាព កម្មវិធី និងវិធានការគោលយោបាយដែលគាំទ្រដល់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងភាពជាអ្នកដឹកនាំរបស់ស្ត្រី បានពង្រឹង និងពង្រីកវិសាលភាព | ៣.១. ក្របខ័ណ្ឌ និងផែនការសកម្មភាពស្តីពីសេដ្ឋកិច្ច ដែលគិតគូរពីសុខុមាលភាព បានរៀបចំនិងអនុវត្ត (បន្ទាត់មូលដ្ឋាន៖ មិនទាន់មាន; ចំណុចដៅ ឆ្នាំ២០២៤៖ ចំនួន ១)<br>៣.២. បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជាដែលបានដំណើរការ ក្នុងការពង្រឹងបណ្តាញ និងការលើកកម្ពស់យេនឌ័រក្នុងធុរកិច្ចនៅកម្ពុជា ក្នុងអាស៊ាន និងលើឆាកអន្តរជាតិ (បន្ទាត់មូលដ្ឋាន៖ ១; ចំណុចដៅ ឆ្នាំ២០២៤-២០២៨ ៖ ចំនួន ៣)<br>៣.៣. ចំនួនកម្មវិធី និងចំនួនសហគ្រិនស្ត្រី ដែលបានទទួលផលពីកម្មវិធីអភិវឌ្ឍន៍សហគ្រិនភាពតាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី ក្នុងភាពជាដៃគូជាមួយនឹងវិស័យឯកជន និងដៃគូពាក់ព័ន្ធ (បន្ទាត់មូលដ្ឋាន៖ ៤ កម្មវិធី សហគ្រិនទទួលផល ១០៨ នាក់; ចំណុចដៅ ឆ្នាំ២០២៥៖ ៣ កម្មវិធី សហគ្រិនទទួលផល ១៥០ នាក់)<br>៣.៤. ចំនួនមជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី ដែលបានអភិវឌ្ឍមុខងារ ឱ្យស្របតាមនិន្នាការបច្ចុប្បន្ន រួមទាំងអភិវឌ្ឍមុខរបរ, ជំនាញវិជ្ជាជីវៈជូនតា និងជំនាញផ្សេងៗ ប្រកបដោយបរិយាប័ន្ន (បន្ទាត់មូលដ្ឋាន៖ ៤ មជ្ឈមណ្ឌល; ចំណុចដៅ ឆ្នាំ២០២៥៖ ៦ មជ្ឈមណ្ឌល)<br>៣.៥. វេទិកាជាតិស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច បានរៀបចំជាប្រចាំឆ្នាំ (បន្ទាត់មូលដ្ឋាន៖ ២; ចំណុចដៅ៖ ចំនួន ៤)<br>៣.៦. កម្មវិធីដំណើរឆ្ពោះទៅមុខដើម្បីភាពជាអ្នកដឹកនាំរបស់ក្មេងស្រី បានរៀបចំ និងអនុវត្ត (បន្ទាត់មូលដ្ឋាន៖ មិនទាន់មាន; ចំណុចដៅ ឆ្នាំ២០២៤៖ ចំនួន ១) |

| | | |
|---|---|---|
| **កសិកម្ម និងទឹក**<br><br>១. ពង្រឹងប្រសិទ្ធភាពខ្សែច្រវាក់ផលិតកម្មកសិកម្ម ប្រកបដោយនិរន្តរភាព ដើម្បីធានាសន្តិសុខស្បៀង និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ | ១. ការបង្កើនតម្លៃសរុបនៃផលិតកម្មដំណាំ និងបរិមាណផលិតកម្មសត្វ | ១.១. តម្លៃសរុបនៃផលិតកម្មដំណាំ (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៤៖ ៨.៨៦៤ លានដុល្លារ; ចំណុចដៅ ឆ្នាំ២០២៥៖ ៩.១៣០ លានដុល្លារ)<br>១.២. បរិមាណផលិតកម្មសត្វ (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៤៖ ៤០០ លានតោន; ចំណុចដៅ ឆ្នាំ២០២៥៖ ៤០៨ លានតោន) |
| | ២. ការបង្កើនតម្លៃនាំចេញផលិតផលកសិកម្ម (ដំណាំ) | ២.១. តម្លៃនាំចេញផលិតផលកសិកម្ម (ដំណាំ) (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៤៖ ៥.២២១ លានដុល្លារ; ចំណុចដៅ ឆ្នាំ២០២៥៖ ៥.២៩០ លានដុល្លារ) |
| | ៣. សហគមន៍កសិកម្មទំនើបត្រូវបានបង្កើត និងដំណើរការធុរកិច្ចបានចំណេញ | ៣.១. សហគមន៍កសិកម្មទំនើបត្រូវបានបង្កើត និងដំណើរការធុរកិច្ចបានចំណេញ (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៤៖ ចំនួន ៣; ចំណុចដៅ ឆ្នាំ២០២៥៖ ចំនួន ៥) |
| ២. ធនធានទឹកត្រូវបានគ្រប់គ្រង អភិវឌ្ឍ និងថែរក្សា និងមានប្រសិទ្ធភាព និងនិរន្តរភាព សម្រាប់ការលូតលាស់ផ្នែកសេដ្ឋកិច្ច, ការកាត់បន្ថយហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួត, និងការរក្សាបានមុខនាទីអេកូឡូស៊ី | ១. ការធានាការប្រើប្រាស់ធនធានទឹកសម្រាប់ស្រោចស្រព តាមរយៈប្រតិបត្តិការ និងការថែទាំ (O&M) ប្រសើរឡើង និងពង្រឹងសមត្ថភាពគ្រប់គ្រងរបស់សហគមន៍កសិករប្រើប្រាស់ទឹក (ស.ក.ប.ទ) | ១.១. សមត្ថភាពស្រោចស្រពផ្ទៃដីដំណាំស្រូវ កើនឡើងដល់ ៣០.០០០ ហិកតា ក្នុង ១ឆ្នាំៗ (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៤៖ ១.៩៧៣.៩៩២ ហិកតា ; ចំណុចដៅ ឆ្នាំ២០២៥៖ ២.០០៣.៩៩២ ហិកតា )<br>១.២. សមត្ថភាពស្រោចស្រពផ្ទៃដីដំណាំរួមផ្សំ កើនឡើងដល់ ៥០០ ហិកតា ក្នុង ១ឆ្នាំៗ (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៤៖ ១៩.២៨៦ ហិកតា; ចំណុចដៅ ឆ្នាំ២០២៥៖ ១៩.៧៨៦ ហិកតា )<br>១.៣. សហគមន៍កសិករប្រើប្រាស់ទឹក ចំនួន ៧ ត្រូវបានរៀបចំបង្កើតឡើងក្នុង១ឆ្នាំៗ (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៤៖ ៦១៦; ចំណុចដៅ ឆ្នាំ២០២៥៖ ៦២៣)<br>១.៤. ចំនួនថែទាំ និងប្រតិបត្តិការ (O&M) នៃប្រព័ន្ធធារាសាស្ត្រ កើនឡើងដល់ ១៧០-២៣០ ក្នុង១ឆ្នាំៗ (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៤៖ ១៧២; ចំណុចដៅ ឆ្នាំ២០២៥៖ ១៨៧)<br>១.៥. សហគមន៍កសិករប្រើប្រាស់ទឹក ចំនួន ២០ ទទួលបានការកសាងនិងពង្រឹងសមត្ថភាពសមស្របប្រចាំឆ្នាំ(បន្ទាត់មូលដ្ឋានឆ្នាំ២០២៤៖ ១៧៧; ចំណុចដៅឆ្នាំ២០២៥៖ ១៩៧) |

| | | |
|---|---|---|
| **ព្រៃឈើ**<br><br>ការបង្កើនការគ្រប់គ្រងធនធានព្រៃផ្តល់ផល ព្រៃសហគមន៍ និងសត្វព្រៃប្រកបដោយនិរន្តរភាព | ១. ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច | ១.១. ចំនួនសហគមន៍ព្រៃឈើទទួលបានប្រកាសពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (បន្ទាត់មូលដ្ឋានឆ្នាំ២០២០៖ ៥៤២; គោលដៅ៖ ៨)<br>១.២. ចំនួនផែនការគ្រប់គ្រងសហគមន៍ព្រៃឈើត្រូវបានអនុម័ត (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៣៖ ១១៥ សហគមន៍ព្រៃឈើ; គោលដៅ៖ ផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ ចំនួន ៤០ ត្រូវបានអនុម័ត)<br>១.៣. ចំនួនសហគមន៍ព្រៃឈើបានទទួលហិរញ្ញប្បទាន ដើម្បីគាំទ្រដួយការអនុវត្តគម្រោងសហគមន៍ព្រៃឈើ (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៣៖ ២០៩; គោលដៅ៖ ៤០)<br>១.៤. ចំនួនទុនវិនិយោគដល់សហគមន៍ព្រៃឈើត្រូវបានបង្កើនសម្រាប់ប្រតិបត្តិការនៃគម្រោងឥណទាន និងមូលនិធិ (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៣៖ ៩៣៥.០០០ ដុល្លារអាមេរិក; គោលដៅ៖ ១.០០០.០០០ ដុល្លារអាមេរិក)<br>១.៥. ចំនួនផ្ទៃដីរេចរឹលត្រូវបានដាំ និងស្តារឈើឡើងវិញ (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២០៖ ១៨.០៦២,៤៨ ហិកតា; គោលដៅ៖ ៦.០០០ ហិកតា)<br>១.៦. ចំនួនកូនឈើបានបណ្តុះ និងចែកជូនសាធារណជន និងសហគមន៍មូលដ្ឋាន (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២០៖ ២០.០៨៣.៧៨៥; គោលដៅ៖ ១.២០០.០០០) |
| | ២. ការធ្វើអោយប្រសើរឡើងនូវធនធានហ្សេនេទិចពូជឈើ | ២.១. ឡូត៍ពិសោធន៍ប្រភេទឈើ និងចំការពូជ ត្រូវបានបង្កើត (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២០៖ ១០១,៥០ ហិកតា; គោលដៅ៖ ៦៤ ហិកតា)<br>២.២. ចំនួនប្រភេទរុក្ខជាតិឈើត្រូវបានសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ ដើម្បីធ្វើឱ្យប្រសើរឡើងនូវចម្រុះប្រភេទរុក្ខជាតិ និងជីវចម្រុះ (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២០៖ ៤; គោលដៅ៖ ២០) |
| | ៣. ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានព្រៃ-ឈើ ត្រូវបានបង្កើត និងប្រតិបត្តិការ | ៣.១. បង្កើត និងដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានព្រៃឈើ (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៣៖ ០; គោលដៅ៖ ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានព្រៃឈើ ត្រូវបានបង្កើត) |
| | ៤. ផែនការយុទ្ធសាស្ត្រព្រៃផ្តល់ផល និងគោលការណ៍ណែនាំ ត្រូវបានរៀបចំ | ៤.១. ផែនការយុទ្ធសាស្ត្រព្រៃផ្តល់ផល រួមទាំងសហគមន៍ព្រៃឈើ ត្រូវបានអនុម័ត (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៣៖ ០; គោលដៅ៖ ផែនការយុទ្ធសាស្ត្រនេះត្រូវបានអនុម័ត)<br>៤.២. ការអភិវឌ្ឍគោលការណ៍ណែនាំកសិ-រុក្ខកម្ម (បន្ទាត់មូលដ្ឋាន ឆ្នាំ២០២៣៖ ០; គោលដៅ៖ សេចក្តីព្រាងចុងក្រោយរបស់គោលការណ៍ណែនាំកសិ-រុក្ខកម្មត្រូវបានរៀបចំ) |

| | | |
|---|---|---|
| **ជលផល**<br><br>ជលផល និងផលិតកម្មវារីវប្បកម្ម ប្រកបដោយនិរន្តរភាព ដើម្បីធានាសន្តិសុខស្បៀង និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន | ១. ការនេសាទ និងការគ្រប់គ្រងជលផល | ១.១. ការនេសាទទឹកសាប និងសមុទ្រ រក្សាបានយ៉ាងតិច ៦០០ ពាន់តោន (ទិន្នន័យមូលដ្ឋាន ឆ្នាំ២០២៣៖ ៥៥០ ពាន់តោន)<br>១.២. កន្លែងអភិរក្សជលផល និងជម្រកជលផល ត្រូវបានការពារយ៉ាងមានប្រសិទ្ធភាព (ទិន្នន័យមូលដ្ឋាន ឆ្នាំ២០២៣៖ ១៥៣ ពាន់ហិកតា)<br>១.៣. ចំនួនសហគមន៍នេសាទដែលមានដំណើរការ និងគ្រប់គ្រងធនធានជលផលប្រកបដោយប្រសិទ្ធភាព កើនបាន៥% (ប្រសិទ្ធភាពនៃការគ្រប់គ្រងដែលត្រូវបានកំណត់ដោយលក្ខណៈវិនិច្ឆ័យដែលមានស្រាប់របស់រដ្ឋបាលជលផល) (ទិន្នន័យមូលដ្ឋាន ឆ្នាំ២០២៣៖ ១៧៥ សហគមន៍នេសាទ ត្រូវនឹង ៣៤% ត្រូវបានវាយតម្លៃថាមានដំណើរប្រកបដោយប្រសិទ្ធភាព) |
| | ២. ការបង្កើនផលិតកម្មវារីវប្បកម្មទឹកសាប និងសមុទ្រ | ២.១. វារីវប្បកម្មទឹកសាប និងសមុទ្រ កើនឡើងប្រចាំឆ្នាំ ៥% (ទិន្នន័យមូលដ្ឋាន ឆ្នាំ២០២៣៖ ៣១៤ ពាន់តោន)<br>២.២. កំណើនប្រចាំឆ្នាំ ២០% នៃកសិដ្ឋានវារីវប្បកម្មដែលមានការបញ្ជាក់ស្តង់ដារ GAqP (ទិន្នន័យមូលដ្ឋាន ឆ្នាំ២០២៣៖ ៧ កសិដ្ឋានវារីវប្បកម្មដែលមានការបញ្ជាក់ GAqP) |
| | ៣. ខ្សែច្រវាក់តម្លៃជលផលត្រូវបានអភិវឌ្ឍ | ៣.១. ការបង្កើនចំនួនសហគ្រាសទទួលបានការបញ្ជាក់គុណភាព និង/ឬវិញ្ញាបនបត្រ CQS និង/ឬ HACCP បាន ២០% ក្នុងមួយឆ្នាំ (ទិន្នន័យមូលដ្ឋាន ឆ្នាំ២០២៣៖ សហគ្រាស ១៧ បានទទួល CQS/HACCP) |
| | ៤. បទប្បញ្ញត្តិ និងសេវាកម្មត្រូវបានពង្រឹង | ៤.១. ចំនួនឯកសារច្បាប់ជលផលដែលបានពង្រាង ដូចជាអនុក្រឹត្យ/ប្រកាស ដោយផ្អែកលើច្បាប់ជលផលថ្មី<br>• ឆ្នាំ២០២៤៖ ច្បាប់ចំនួន ២ (ច្បាប់អនុម័តកិច្ចព្រមព្រៀងឧបត្ថម្ភធនជលផល និងច្បាប់ស្តីពីជលផលថ្មី), អនុក្រឹត្យចំនួន ២, និងប្រកាសចំនួន ៦<br>• ឆ្នាំ២០២៥៖ អនុក្រឹត្យចំនួន ២ និងប្រកាសចំនួន ៥<br>៤.២. ភាគរយនៃការសម្រេចបាន AWPB (ទិន្នន័យមូលដ្ឋាន ឆ្នាំ២០២៣៖ ៩៥%) |

| | | |
|---|---|---|
| **ការដោះមីន**<br><br>កម្មវិធីសកម្មភាពមីនជាតិដែលឆ្លើយតបទៅនឹងបញ្ហាសន្តិសុខមនុស្សជាតិ និងគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម | ១. ដីដែលដឹងថាមានមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម (ស.ផ.ស.) ត្រូវបានរំដោះ ដើម្បីគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម | ១.១. រំដោះផ្ទៃដីដែលសង្ស័យមានមីន/ស.ផ.ស. ឱ្យបាន ១៧.១០០ ហិកតា ក្នុងមួយឆ្នាំ<br>១.២. ផ្ទៃដីដែលបានសម្អាតមីន និង ស.ផ.ស. រួចទាំងអស់ ត្រូវបានប្រើប្រាស់សម្រាប់គាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម |
| | ២. ការកាត់បន្ថយចំនួនជនរងគ្រោះដោយសារមីន/ស.ផ.ស. | ២.១. ចំនួនជនរងគ្រោះដោយសារមីន/ស.ផ.ស. ត្រូវបានថយចុះ ១០% ពីមួយឆ្នាំទៅមួយឆ្នាំ |
| | ៣. ជនរងគ្រោះដោយសារមីន/ស.ផ.ស. បានយល់ដឹងពីសិទ្ធិរបស់ពួកគេ និងទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រ និងផ្លូវចិត្ត និងសេវាកម្មស្តារលទ្ធភាពពលកម្មកាយសម្បទា ព្រមទាំងលើកកម្ពស់ការស្វែងរកការគាំទ្រមតិសម្រាប់ជនពិការក្នុងវេទិកាជាតិ-អន្តរជាតិ | ៣.១. ជនរងគ្រោះដោយសារមីន/ស.ផ.ស. ចំនួន ៤.០០០ នាក់ ក្នុងមួយឆ្នាំ បានយល់ដឹងពីសិទ្ធិរបស់ពួកគេ និងការថែទាំផ្នែកវេជ្ជសាស្ត្រនិងផ្លូវចិត្ត និងសេវាកម្មស្តារលទ្ធភាពពលកម្មកាយសម្បទា<br>៣.២. ជនរងគ្រោះដោយសារមីន/ស.ផ.ស. ចំនួន ១.០០០ នាក់ ក្នុងមួយឆ្នាំ បានទទួលការថែទាំផ្នែកវេជ្ជសាស្ត្រនិងផ្លូវចិត្ត និងសេវាកម្មស្តារលទ្ធភាពពលកម្មកាយសម្បទា<br>៣.៣. ការចូលរួមយ៉ាងសកម្មរបស់អាជ្ញាធរមីនក្នុងវេទិកាកិច្ចប្រជុំជាតិនិងអន្តរជាតិ ដើម្បីកិច្ចការងារគាំទ្រ និងលើកស្ទួយជនរងគ្រោះដោយសារមីន/ស.ផ.ស. |
| **បរិស្ថាន និងការប្រែប្រួលអាកាសធាតុ***<br><br>១. គម្របព្រៃឈើកម្ពុជាមានចំនួន ៥២% | ១. គម្របព្រៃឈើកម្ពុជាមានចំនួន ៤៩% | ១.១. គម្របព្រៃឈើកម្ពុជាបានកើនឡើងចំនួន ១% (១៨១.០៣៥ ហិកតា)<br>(បន្ទាត់មូលដ្ឋាន ឆ្នាំ២០១៨៖ គម្របព្រៃឈើកម្ពុជាមានចំនួន ៤៨%) |
| ២. កម្ពុជាមានស្ថានីយបណ្តុះកូនឈើថ្នាក់តំបន់ ចំនួន ៥ កន្លែង | ១. កម្ពុជាមានស្ថានីយបណ្តុះកូនឈើថ្នាក់តំបន់ចំនួន ១ កន្លែង | ១.១. ស្ថានីយបណ្តុះកូនឈើថ្នាក់តំបន់ ចំនួន ១ កន្លែង ត្រូវបានសាងសង់<br>(បន្ទាត់មូលដ្ឋាន៖ ស្ថានីយបណ្តុះកូនឈើថ្នាក់តំបន់មានចំនួន ០ កន្លែង) |
| ៣. តំបន់ស្នូលនៃតំបន់ការពារធម្មជាតិទាំងអស់ត្រូវបានកំណត់ ដើម្បីការពារគម្របព្រៃ និងប្រព័ន្ធអេកូឡូស៊ី | ១. តំបន់ស្នូលនៃតំបន់ការពារធម្មជាតិចំនួន ១០ ត្រូវបានកំណត់ ដើម្បីការពារគម្របព្រៃ ប្រព័ន្ធអេកូឡូស៊ី | ១.១. អនុក្រឹតស្តីពីការកំណត់តំបន់ស្នូលនៃតំបន់ការពារធម្មជាតិ ចំនួន ៥ តំបន់ បន្ថែមទៀត<br>(បន្ទាត់មូលដ្ឋាន៖ តំបន់ស្នូលនៃតំបន់ការពារធម្មជាតិ ចំនួន ៥ តំបន់ ត្រូវបានកំណត់ រួមមានដែនជម្រកសត្វព្រៃពាមក្រសោប ដែនជម្រកសត្វព្រៃភ្នំព្រិច ដែនជម្រកសត្វព្រៃលំផាត់ ដែនជម្រកសត្វព្រៃស្រែពក ឧទ្យានជាតិវីរៈជ័យ) |

*សូចនាករតាមដានត្រូវបានកំណត់ដោយក្រសួងបរិស្ថាន សម្រាប់ការអនុវត្ត និងតាមដានវឌ្ឍនភាព

| | | |
|---|---|---|
| ៤. តំបន់ការពារធម្មជាតិទាំងអស់មានផែនការគ្រប់គ្រងដែលមានសុពលភាព | ១. តំបន់ការពារធម្មជាតិ ចំនួន ១០ តំបន់ មានផែនការគ្រប់គ្រងដែលមានសុពលភាព | ១.១. ផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ ចំនួន ៥ តំបន់បន្ថែម ទទួលបានការឯកភាព និងដាក់ឱ្យអនុវត្ត (បន្ទាត់មូលដ្ឋាន៖ តំបន់ការពារធម្មជាតិ ចំនួន ៥ មានផែនការគ្រប់គ្រង រួមមានដែនជម្រកភ្នំសំកុស ដែនជម្រកសត្វព្រៃស្រែពក តំបន់រ៉ាមសារបឹងទន្លេឆ្មារ តំបន់រ៉ាមសារព្រែកទាល់ ដែនជម្រកសត្វព្រៃឱរ៉ាល់) |
| ៥. ៦៨ ឃុំ/សង្កាត់ដែលបានបញ្ជ្រាបការងារបន្សាំ និងការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ | ១. ១៧ ឃុំ ដែលបានបញ្ជ្រាបការងារបន្សាំ និងការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ | ១.១. ចំនួនឃុំ/សង្កាត់ទូទាំងប្រទេស សរុប ១.៦៥២<br>១.២. ឃុំ ដែលបានបញ្ជ្រាបការប្រែប្រួលអាកាសធាតុ មានចំនួន ១៤៨ |
| ៦. បរិមាណឧស្ម័នផ្ទះកញ្ចក់ចំនួន ២៦,១៦ MtCO2e បានកាត់បន្ថយ | ១. បរិមាណឧស្ម័នផ្ទះកញ្ចក់ ចំនួន ៦,៥៤ MtCO2e ត្រូវបានកាត់បន្ថយ | ១.១. បរិមាណឧស្ម័នផ្ទះកញ្ចក់ ចំនួន ៦,៥៤ MtCO2e កាត់បន្ថយក្នុង១ឆ្នាំ |

**<u>បញ្ហកោណទី ៥</u>** : **<u>ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល</u>** - រាជរដ្ឋាភិបាលបានចាត់ទុកបច្ចេកវិទ្យាឌីជីថលជាកាតាលីករថ្មីដ៏មានសារៈសំខាន់ ដែលមានសក្តានុពលភាព និងកាលានុវត្តភាពក្នុងការជំរុញកំណើនផលិតភាពសេដ្ឋកិច្ច និងសង្គម ក៏ដូចជាប្រសិទ្ធភាពនៃការងាររដ្ឋបាល ។ ក្នុងទិសដៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលផ្តោតលើអាទិភាពចំនួន ៥ : ១) ការកសាងរដ្ឋាភិបាលឌីជីថល និងពលរដ្ឋឌីជីថល; ២) ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ធុរកិច្ចឌីជីថល, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធនវានុវត្តន៍ឌីជីថល; ៣) ការកសាង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល; ៤) ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល និង ៥) ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ (ទំ. ៨៨-៨៩)។